## ផលិតផលធានារ៉ាប់រងភារៈទទួលខុសត្រូវជាសាធារណៈ

អាជីវកម្មរបស់លោកអ្នកអាចប្រឈមនឹងហានិភ័យជារៀងរាល់ថ្ងៃ មធ្យោបាយតែមួយគត់ដើម្បីការពារទ្រព្យសម្បត្តិរបស់លោកអ្នកគឺ ត្រូវមានកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវជាសាធារណៈដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់អាជីវកម្មរបស់លោកអ្នក។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវទូទៅ អាចរួមបញ្ចូលនូវការធានារ៉ាប់រងបែបសម័យមុន និងយន្តការផ្តល់ហិរញ្ញប្បទានលើហានិភ័យផ្សេងៗគ្នា ដើម្បីជួយគ្រប់គ្រងហានិភ័យនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុន។

**ក្រុមហ៊ុន នីវ៉ា អ៊ិនសួរេន (ខេមបូឌា) ម.ក** ផ្តល់ជូនលោកអ្នក នូវការធានារ៉ាប់រងចំពោះការធានាខុសត្រូវដោយស្របច្បាប់ ដើម្បីទូទាត់សំណងដល់ភាគីតតិយជនដែលទទួលរងរបួសដោយចៃដន្យ ឬស្លាប់ ឬខូចខាតទ្រព្យសម្បត្តិ ដែលបណ្តាលមកពីការធ្វេសប្រហែសនៃប្រតិបត្តិការអាជីវកម្មរបស់លោកអ្នក។ ប្រសិនបើលោកអ្នកជាម្ចាស់កម្មសិទ្ធិបរិវេណមួយដែលសាធារណជនទូទៅចេញចូលញឹកញាប់ នោះលោកអ្នកនឹងត្រូវមានការធានារ៉ាប់រងនេះ។

## តើកិច្ចសន្យានេះធានារ៉ាប់រងទៅលើអ្វីខ្លះ?

កិច្ចសន្យាធានារ៉ាប់រងនេះធានាលើការទទួលខុសត្រូវស្របច្បាប់ ដែលអាចកើតឡើងពីការធ្វេសប្រហែសដែលនាំឱ្យមានការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិរបស់ភាគីតតិយជន ការរងរបួសរាងកាយ ឬការស្លាប់ និងការចំណាយផ្នែកច្បាប់ដែលត្រូវបានធ្វើឡើងដើម្បីការពារការទទួលខុសត្រូវ ដោយមានការយល់ព្រមពីក្រុមហ៊ុនធានារ៉ាប់រង។

**កំណត់សម្គាល់:** ភាគីតតិយជន គឺជាសាធារណជនទូទៅទាំងឡាយ លើកលែងតែបុគ្គលិក ម្ចាស់អាជីវកម្ម ឬសាច់ញាតិរបស់ម្ចាស់អាជីវកម្ម។

កិច្ចសន្យាធានារ៉ាប់រងនេះក៏នឹងធ្វើសំណងជូនលោកអ្នកផងដែរនូវថ្លៃសេវាកម្មផ្នែកច្បាប់ដូចខាងក្រោម:

- ថ្លៃសេវាក ម្មផ្នែកច្បាប់ ចំពោះការប្តឹងទាមទារសំណងពីភាគីតតិយជន
- ការចេញថ្លៃសេវាកម្មផ្នែកច្បាប់លុះត្រាតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំ

កិច្ចសន្យាធានារ៉ាប់រងនេះ អាចតម្រូវឱ្យរួមបញ្ចូលទាំង:

- ការទទួលខុសត្រូវដែលកើតឡើងដោយសារការប្រើប្រាស់អាងហែលទឹក
- ការពុលចំណីអាហារ
- ការសង្គ្រោះបឋម
- ការខូចខាតដល់យានយន្តរបស់អតិថិជន នៅក្នុងកន្លែងចតរថយន្ត (មិនទទួលខុសត្រូវក្នុងករណីចោរលួច)
- ការឆេះ ឬផ្ទុះដែលបង្កឱ្យខូចខាត ឬរងរបួសដល់អ្នកជិតខាង ឬអ្នកធ្វើដំណើរ។

**កំណត់សម្គាល់:** រាល់ ខ ចែង និងលក្ខខណ្ឌជាក់លាក់ទាំងអស់ត្រូវយោងទៅលើអត្ថន័យដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនយើងខ្ញុំ។ សូមជូនព័ត៌មានជាបន្ទាន់មកក្រុមហ៊ុនយើងខ្ញុំ ក្នុងករណីដែលលោកអ្នកមានបណ្តឹងទាមទារសំណងណាមួយពីភាគីតតិយជន។

## តើកិច្ចសន្យាធានារ៉ាប់រងនេះមិនធានាទៅលើអ្វីខ្លះ?

យើងខ្ញុំនឹងធ្វើសំណងក្នុងករណីដែលលោកអ្នកមានកាតព្វកិច្ចទទួលខុសត្រូវស្របច្បាប់ចំពោះសំណងរដ្ឋប្បវេណីលើភាគីតតិយជន ហើយសំណងទាំងនោះកើតឡើងដោយសារតែកំហុស ឬការធ្វេសប្រហែសនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់លោកអ្នក។

ករណីមិនធានាលម្អិត សូមយោងទៅលើ**ឧបសម្ព័ន្ធ១**

## តើអ្នកណាខ្លះត្រូវការកិច្ចសន្យាធានារ៉ាប់រងនេះ?

កិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវជាសាធារណៈនេះ មានសារៈសំខាន់ចំពោះម្ចាស់អាជីវកម្មទាំងអស់។ វាជួយការពារលោកអ្នក និងអាជីវកម្មរបស់លោកអ្នកពីការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីរបួសលើរូបរាងកាយ ឬស្លាប់ ឬខូចខាតទ្រព្យសម្បត្តិរបស់ភាគីតតិយជននៅក្នុងបរិវេណអាជីវកម្មរបស់លោកអ្នកដោយសារតែកំហុស ឬការធ្វេសប្រហែសដោយអចេតនារបស់លោកអ្នក។

## តើតម្លៃប៉ុន្មានដែលខ្ញុំគួរតែដាក់ធានា?

ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង គឺអាស្រ័យលើដែនកំណត់នៃការទទួលខុសត្រូវ។ ដែនកំណត់នៃការទទួលខុសត្រូវគឺអាស្រ័យលើសក្តានុពលនៃបណ្តឹងទាមទារសំណងរបស់តតិយជន។

## តើអ្វីទៅជារយៈពេលនៃការធានារ៉ាប់រង?

រយៈពេលនៃការដាក់ធានារ៉ាប់រងគឺ ១២ ខែ។

## កត្តាដែលកំណត់បុព្វលាភធានារ៉ាប់រង

- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- មុខងាររបស់អគារ
- អាសយដ្ឋានដែលត្រូវធានារ៉ាប់រង និងទំហំនៃបរិវេណអាជីវកម្ម
- ការប្រើប្រាស់អគាររបស់អ្នកជិតខាងដែលនៅជុំវិញ
- ប្រវត្តិនៃការទាមទារសំណងពីមុន

## តើខ្ញុំអាចចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រងនេះបានដោយរបៀបណា?

សូមទំនាក់ទំនងមកយើងខ្ញុំ ដើម្បីទទួលបានការណែនាំពីរបៀបធានារ៉ាប់រងលើទ្រព្យសម្បត្តិរបស់លោកអ្នក។

**កំណត់សម្គាល់:** រាល់ ខ ចែង និងលក្ខខណ្ឌជាក់លាក់ទាំងអស់ត្រូវយោងទៅលើអត្ថន័យដែលមានចែងនៅក្នុងលក្ខខណ្ឌលម្អិតនៃកិច្ចសន្យាធានារ៉ាប់រងរបស់យើងខ្ញុំ។


ក្រុមហ៊ុន នីវ៉ា អ៊ិនសួរេន(ខេមបូឌា)ម.ក

NEWA INSURANCE (CAMBODIA) PLC. 新安保險(柬埔寨)有限公司

ផ្ទះលេខ៥អឺ មហាវិថីសហព័ន្ធរុស្ស៊ី ផ្លូវលេខ១១០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (+៨៥៥) ២៣ ៩៥៨ ៨៩៩/៩៥៦ ៨៦៨/ ៩៥៦ ៦៨៨

លេខទូរស័ព្ទប្រចាំការ២៤ម៉ោង : (+៨៥៥) ១៧ ៩៩៩ ៧៥២/៩៩៩ ៧៥៣

ទូរសារ : (+៨៥៥) ២៣ ៩០១ ៣៨៦/ ៩០១ ៣៨៥

សារអេឡិចត្រូនិច : info@newa-kh.com

គេហទំព័រ : www.newa-kh.com


ក្រុមហ៊ុន នីវ៉ា អ៊ិនសួរេន(ខេមបូឌា)ម.ក

NEWA INSURANCE (CAMBODIA) PLC. 新安保險(柬埔寨)有限公司

# ផលិតផលធានារ៉ាប់រង ភារៈទទួលខុសត្រូវជាសាធារណៈ

PUBLIC LIABILITY INSURANCE